**សំរេច**

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន ជារដ្ឋលេខាធិការ ស្តីទី នៃក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនជំនួសឯកឧត្តម **ស៊ុយ សែម** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៦ រហូតដល់ ឯកឧត្តមបញ្ចប់បេសកកម្ម ។

**ប្រការ ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ម៉ុក ម៉ារ៉េត** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

## សេចក្តីសំរេចលេខ ២១ សសរ

## ស្តីពីការបង្កើតប្រធានគណៈកម្មការរៀបចំបុណ្យសព

**មាត្រា ១** : ត្រូវបានបង្កើតប្រធានគណៈកម្មការបុណ្យសពសម្តេចចក្រី **ញឹក ជូឡុង** ឧត្តមទីប្រឹក្សា ព្រះមហាក្សត្រដូចមានរាយនាមខាងក្រោម ÷

១–ឯកឧត្តម **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីបរមរាជវាំង ជាប្រធាន

២–ឯកឧត្តម ឧត្តមសេនិយឯក **ទៀ បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៣–ឯកឧត្តម ឧត្តមសេនិយឯក **ទា ចាំរ៉ាត់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៤–ឯកឧត្តម ឧត្តមសេនិយឯក **ខេព ប៉ែន** ឧត្តមទីប្រឹក្សាព្រះមហាក្សត្រ ជាសមាជិក

៥–ឯកឧត្តម ឧត្តមសេនិយឯក **កែ គឹមយ៉ាន** នាយអគ្គសេនាធិការ ជាសមាជិក

៦-ឯកឧត្តម ឧត្តមសេនីយឯក **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

៧-ឯកឧត្តម **ឯក សេរីវឌ្ឍ** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

៨-ឯកឧត្តម ឧត្តមសេនីយឯក **នួន សុខ** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

៩-ឯកឧត្តម ឧត្តមសេនីយឯក **ញ៉ឹក ប៊ុនឆៃ** នាយរងអគ្គសេនាធិការ ជាសមាជិក

១០-ឯកឧត្តម ឧត្តមសេនីយឯក **ប៉ាន់ ថៃ** នាយខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១១-ឯកឧត្តម ឧត្តមសេនីយឯក **ប៊ុល សារឿន** នាយរងអគ្គសេនាធិការ ជាសមាជិក

១២-ឯកឧត្តម ឧត្តមសេនីយឯក **មាស សុភា** នាយរងអគ្គសេនាធិការ ជាសមាជិក

១៣-ឯកឧត្តម ឧត្តមសេនីយឯក **ជឿន ជែល** នាយកទីចាត់ការអធិការកិច្ចអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៤-ឯកឧត្តម ឧត្តមសេនីយឯក **ប៊ុល សុត** នាយកទីចាត់ការហិរញ្ញវត្ថុអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៥-ឯកឧត្តម ឧត្តមសេនីយទោ **ខឹម សោភ័ណ្ឌ** នាយរងអគ្គសេនាធិការ ជាសមាជិក

១៦-ឯកឧត្តម ឧត្តមសេនីយទោ **ផា ថនចាន់**នាយកទីចាត់ការទូទៅអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៧-ឯកឧត្តម ឧត្តមសេនីយទោ **ឡុង សុភាព**នាយកទីចាត់ការយុទ្ធអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៨-ឯកឧត្តម ឧត្តមសេនីយទោ **លី ដេត** នាយកទីចាត់ការបុគ្គលិកអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៩-ឯកឧត្តម ឧត្តមសេនីយទោ **ឈុំ សុជាតិ** នាយកនាយកដ្ឋានស្រាវជ្រាវអគ្គបញ្ជាការដ្ឋាន ជាសមាជិក

២០-អ្នកអង្គម្ចាស់នាវាឧត្តម **ទ៉ាត់ រ៉ានី** មេបញ្ជាការទ័ពអាកាស ជាសមាជិក

២១-ឧត្តមសេនីយត្រី **ម៉ុខ សំផន** នាយក នាយកដ្ឋានថវិកា ជាសមាជិក

២២-ឧត្តមសេនីយត្រី **ទ៉ាន់ ប៊ុននី** មេបញ្ជាការរងកងរាជអាវុធហត្ថជាតិ ជាសមាជិក

**មាត្រា ២** : គណៈកម្មការមានភារកិច្ចចាត់ចែងពិធីបុណ្យសព តាមប្រពៃណី និង ទំនាក់ទំនងបណ្តាស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីដំណើរការបុណ្យសពនេះអោយបានអធិកអធម ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ អគ្គបញ្ជាការដ្ឋាន និង សាមីខ្លួនត្រូវអនុវត្តន៍ តាមសេចក្តីសំរេចនេះ ចាប់ពីឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

# II ការងារបណ្តាក្រសួង

## ១–ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០៨០ សហវ.ប្រក**

**ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសម្របសំរួល**

**និងកែទំរង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាស